កម្មវិធីនៃការសិក្សានៅផ្ទះនឹងកើតមានឡើងក្នុងពេលឆាប់ៗនេះ។ កម្មវិធីចែកអាហារនឹងត្រូវផ្លាស់ប្តូរ។

ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី២៣មិនា ក្រសួងអប់រំឡុងប៊ីចនឹងផ្ញើព័ត៌មានអំពីការសិក្សានៅផ្ទះសម្រាប់ការសិក្សាទូទៅ និងសិស្សក្នុងកម្មវិធីអប់រំពិសេសហើយនិងក្រុមគ្រួសារសិស្ស។ កម្មវិធីនៃការសិក្សានៅផ្ទះនេះគឺសម្រាប់ក្នុងកំឡុងរយៈពេលពីថ្ងៃច័ន្ទ ទី២៣មិនា ទៅដល់ថ្ងៃព្រហស្បតិ៍ ទី៩មេសា។ មេរៀននិងធនធានសិក្សាត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់កម្មវិធី ការសិក្សាជាបន្ត នៅក្នុងកំរិតថ្នាក់របស់សិស្ស រហូតដល់ថ្ងៃទី៩មេសា(ដែលគឺជាថ្ងៃមុនថ្ងៃបុណ្យឈប់សម្រាកនៅថ្ងៃទី១០មេសា និងការឈប់សម្រាកនិទាឃរដូវមួយសប្តាហ៍ក្នុងសប្តាហ៍បន្ទាប់)។ កម្មវិធីសិក្សានៅផ្ទះនេះនឹងមិនមានកត់ជាពិន្ទុទេ។

ថែមពីនេះទៀត ចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី២៣មិនា សេវាកម្មចែកអាហារនៅសាលានឹងបន្តចែកឱ្យពីម៉ោង៨ទៅ៩ព្រឹកសម្រាប់អាហារព្រឹក និងពីម៉ោង១១:៣០ព្រឹកទៅដល់ម៉ោង១:00 រសៀលសម្រាប់អាហារថ្ងៃត្រង់នៅគ្រប់សាលារៀនទាំងអស់លើកលែងតែសាលា Beach/Reid, Browning, CAMS, Lowell, Millikan, Naples, PAAL, Renaissance, Sato and Stanford ។ សាលារៀនទាំងនោះឈប់ផ្តល់សេវាចែកអាហារទៀតហើយនៅក្នុងរយៈពេលដែលសាលារៀនបិទទ្វារ។ ចាប់ផ្តើមពីថ្ងៃអង្គារទី២៤មិនា សាលារៀនដែលនៅចែកអាហារនឹងប្តូរទៅចែកតែមួយពេលប៉ុណ្ណោះ គឺពីម៉ោង១១:៣០ព្រឹកទៅដល់ម៉ោង១រសៀល។ នៅពេលនោះ សិស្សនឹងបានទទួលអាហារថ្ងៃត្រង់ ហើយនិងអាហារព្រឹកសម្រាប់ពេលព្រឹកនៅថ្ងៃស្អែកផងដែរ។

សិស្សដែលរៀននៅសាលាទាំងឡាយដែលឈប់ផ្តល់សេវាចែកអាហារអាចទៅយកអាហារនៅសាលាដែលនៅជិតផ្ទះជាងគេ។ រកមើលផែនទីសាលារៀនរបស់ LBUSD នៅ lbschools.net រួចចុចលើពាក្យ ABOUT បន្ទាប់មកចុចលើពាក្យ Map.

បើសិនជាអ្នកត្រូវការកុំព្យូទ័រ ក្រុមប៊ុគ Chromebook ឧបករណ៍នេះនឹងមានឱ្យប្រើចាប់ពីថ្ងៃពុធទី២៥មិនាទៅ។ សាលារៀនក៏អាចផ្តល់ព័ត៌មានអំពីការមានលទ្ធភាពប្រើប្រាស់អ៊ិនធើនែតនៅផ្ទះផងដែរ ចំពោះគ្រួសារណាដែលមិនមានអ៊ិនធើនែតនៅផ្ទះ។ ព័ត៌មានថែមទៀតនឹងផ្តល់ជូននៅសប្តាហ៍ក្រោយ។ សម្ភារៈសិក្សានៅផ្ទះនឹងមានផ្តល់ជាក្រដាសដល់គ្រួសារណាដែលត្រូវការ ចាប់ផ្តើមនៅថ្ងៃអង្គារ ទី២៤មិនា។